**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២០-៥២៩ ឥ.ស.ណ

ថ្ងៃ សុក្រ ៤ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២០

**ជម្រាបមក**

**លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ សេចក្តីជូនដំណឹងអំពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**យោង** ៖
- អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃពុធ ០៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង
- លិខិតលេខ ៦០៣៨ សហវ.គសហ ចុះថ្ងៃពុធ ៣រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា ឲ្យបានជ្រាបថា បច្ចុប្បន្ន ធុរជនត្រូវប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ដើម្បីអាចបង្កើតគណនីនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ យោងតាមអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃពុធ ០៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការចុះបញ្ជីអាជីវកម្មយន្តការថ្មីត្រូវធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមួយ ដែលត្រូវបានប្រកាសដាក់ឲ្យដំណើរការជាផ្លូវការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ហើយវិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ផ្សេងៗ ត្រូវចេញជាទម្រង់ឌីជីថល ដែលធុរជនអាចបោះពុម្ព (Print) ដោយខ្លួនឯង និងយកទៅប្រើប្រាស់ជាផ្លូវការបាន ដោយមិនបាច់តម្រូវឲ្យយកឯកសារដែលមានត្រាច្បាប់ដើមដូចមុនទៀតទេ។ វិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ផ្សេងៗក្នុងទម្រង់ឌីជីថល អាចបញ្ជាក់ពីភាពត្រឹមត្រូវបានតាមរយៈលេខសម្គាល់សហគ្រាស ដែលអាចផ្ទៀងផ្ទាត់បានលើគេហទំព័រចុះបញ្ជីពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមទទួលយកឯកសារដែលបោះពុម្ព (Print) ចេញពីឯកសារទម្រង់ឌីជីថល ស្របតាមយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**អ.ម. ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណនរៈ**

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧